**សមាគមមិត្តខ្មែរក្រោមដើម្បីវប្បធម៌ប្រចាំកាណាដាភាគខាងលិច**
WESTERN CANADA KKF CULTURAL ASSOCIATION
2949 - 17 Avenue SE, Suite 554, Calgary, AB, T2A 0P9 Canada
Email: info@kampucheakrom.ca Home: 403-601-6590

# លិខិតនិមន្តនិងអញ្ជើញ

យើងខ្ញុំជាគណៈកម្មការសមាគមមិត្តខ្មែរក្រោមដើម្បីរក្សាវប្បធម៌ប្រចាំប្រទេសកាណាដាភាគខាងលិច ព្រមទាំងសមាគមនិងបងប្អូនខ្មែរទាំងអស់ សូមអារាធនានិមន្តនិងអញ្ជើញអស់លោក–លោកស្រីចូលរួមកម្មវិធីបុណ្យរំលឹកខួបលើកទី៦៥នៃទិវាបាត់បង់ទឹកដីខ្មែរកម្ពុជាក្រោមនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ – ទី០៤ ខែមិថុនា ឆ្នាំ២០១៤ នៅពេលដែលអាណានិគមបារាំងបានកាត់ទឹកដីកម្ពុជាក្រោមឱ្យទៅស្ដេច**បាវដាយ**ដោយអត្តនោមតិ ។ចាប់ពីពេលនោះមកខ្មែរក្រោមបានបន្តទទួលរងនូវការកៀបសង្កត់បំបិទសិទ្ធិគ្រប់បែបយ៉ាង ទាំងការគោរពព្រះពុទ្ធសាសនា ប្រពៃណីទំនៀមទំលាប់ វប្បធម៌ អក្សរសាស្ត្រជាដើម ។ល។ លើសពីនេះទៅទៀតអត្តសញ្ញាណនិងការរស់រានរបស់ខ្មែរកម្ពុជាក្រោមកំពុងស្ថិតក្រោមការគំរាមគំហែងយ៉ាងខ្លាំងនាពេលបច្ចុប្បន្ន ។

ពីធីបុណ្យរំលឹកខួបជារៀងរាល់ឆ្នាំនេះមានគោលបំណងសំខាន់៧ដូចជា:

១. ជាការអប់រំដល់យុវជនខ្មែរជំនាន់ក្រោយអោយដឹងអំពីប្រវត្តិសាស្ត្រខ្លួន,

២. ជាការបង្ហាញទឹកចិត្តសាមគ្គីភាពរបស់ខ្មែរយើងពីគ្រប់មជ្ឈដ្ឋានទូទាំងពិភពលោកមិនថាឡើយ**ខ្មែរក្រោម ខ្មែរលើឬខ្មែរកណ្ដាលគឺយើងខ្មែរតែមួយដែលមានសាច់ឈាមខ្មែរដូចគ្នា**,

៣. ជាការបំពេញភារកិច្ចផ្នែករក្សាប្រពៃណី ទំនៀមទំលាប់ ព្រះពុទ្ធសាសនា និងមនុស្សធម៌,

៤. ជាការសហការយ៉ាងជិតស្និទ្ធជាមួយសហគមន៍អន្តរជាតិក្នុងកិច្ចការពារសិទ្ធិមូលដ្ឋានរបស់មនុស្សជាតិ។

## កម្មវិធីបុណ្យរួមមាន

<u>ថ្ងៃសុក្រ ២កើត ខែជេស្ឋ ឆ្នាំមមី ព.ស.២៥៥៨ត្រូវនឹងទី៣០ ខែឧសភា ឆ្នាំ២០១៤</u>

–ម៉ោង០៦ល្ងាច= ជួបជុំសមាជិក–សមាជិកានិងភ្ញៀវកិត្តិយសទាំងអស់នៅវត្ត 10830-106 Street, Edmonton NW ,AB T5H 2Y2 នមស្សការព្រះរតនត្រ័យ សមាទានសីល ចំរើនព្រះបរិត្តនិងសំដែងធម្មទេសនា ។

<u>ថ្ងៃសៅរ៍ ៣កើត ខែជេស្ឋ ឆ្នាំមមី ព.ស.២៥៥៨ត្រូវនឹងទី៣១ ខែឧសភា ឆ្នាំ២០១៤</u>

–ម៉ោង០៦ព្រឹក= ប្រគេនយាគូដល់ព្រះសង្ឃនៅវត្ត

–ម៉ោង០៩ព្រឹក= ជួបជុំសមាជិកទាំងអស់នៅ**Dutch Canadian Center, 13312 142 Street, Edmonton AB T5L 4T3** នមស្សការព្រះរតនត្រ័យ សមាទានសីល និងរាប់បាត្របង្សុកុលឧទ្ទិសមគ្គផលដល់បុព្វការីជន ។ រវាងម៉ោង១២:៣០ដល់ម៉ោង២:៣០ នឹងមានវគ្គសិក្ខាសាលាស្ដីពីទុក្ខវេទនានិងសិទ្ធិសេរីភាពរបស់ខ្មែរក្រោម ។

–ម៉ោង០៦ល្ងាច= ជួបជុំសមាជិកទាំងអស់នៅ **Dutch Canadian Center, 13312 142 Street, Edmonton AB T5L 4T3** មានពីធី

–ម៉ោង៧ល្ងាច=គណៈកម្មការនាយកឡើងថ្លែងសុន្ទរកថាអំពីសកម្មភាពរបស់សហព័ន្ធខ្មែរក្រោមពិភពលោក

–ម៉ោង៨:៣០ល្ងាច=**កម្មវិធីរាំកំសាន្តសប្បាយជាមួយក្រុមតន្ត្រីនិងក្រុមចំរៀងខ្មែរល្បីៗ ដោយឥតមានលក់សំបុត្រ(បរិច្ចាគតាមសទ្ធា)។** <u>**ពត៌មានបន្ថែមសូមទាក់ទង**</u>

តាំង ផេង ៤០៣–៣៤៣–៩១១៤, ឡែម លុយ ៧៨០–៦៧២–៤៤៦៦, ដាវ ឫទ្ធិ ៤០៣–៦៤៩–៣៨៧៣
ទ្រីវ ឆេផុង ៧៨៩០–៦៧២–៥៣១០, សឺន លី ៤០៣–៦៨៩–០៦៩៩, ដាវ ហួន ៤០៣–៦៦៩–២១១៩,
សឺន វ៉ា ៤០៣–៩៦៩–៩៨៤២ Email: info@kampucheakrom.ca

សមាគមមិត្តខ្មែរក្រោមដើម្បីវប្បធម៌ប្រចាំកាណាដាភាគខាងលិច
WESTERN CANADA KKF CULTURAL ASSOCIATION
2949 - 17 Avenue SE, Suite 554, Calgary, AB, T2A 0P9 Canada
Email: info@kampucheakrom.ca  Home: 403-601-6590

# 65TH ANNIVERSARY COMMEMORATION

We are members of the Western Canada Khmer Kampuchea Krom Friend Association in partnering with Khmer associations would like to invite Venerable Monks and distinguished guests to participate with our 65th Anniversary Commemoration of the loss of Khmer Kampuchea Krom land to Vietnamese in June 04, 1949 – June 04, 2014. In that time, French protectorate abused the Kingdom of Cambodia by allowing Khmer Kampuchea Krom land controlled by Vietnamese Emperor Bao Dai. Since then, Khmer Kampuchea Krom people have been perpetually violated their rights including the practice of Buddhism, traditions, culture and language etc. More than this, the Khmer Kumpuchea Krom's identity and their fate are under grave threat of assimilation and extermination at the present. Thus, we hold this commemoration annually in order:

- To educate the young people about the history
- To collectively work for unity with all Khmer people regardless of where they come from
- To preserve culture, tradition, Buddhism and enhance humanitarian services and
- To engage with the international communities in the struggle for the respect of human rights and dignities of mankind.

## TENTATIVE SCHEDULE

### Friday, May 30th, 2014

- 6:00PM = Arrival of members and distinguished guests for Parita Chanting and Dhamma Preaching at temple: **10830-106 Street, Edmonton NW, AB T5H 2Y2**

### Saturday, May 31st, 2014

- 6:00AM = Offer breakfast (Yaku) to the Bhikkhu Monks at the temple
- 9AM= Arrival of members and distinguished guests at **Dutch Canadian Center, 13312 142 Street, Edmonton AB T5L 4T3** to worship Triple Gem, Observe Five Precepts, Offer alms-food to the Bhikkhu Monks to dedicate merits to our ancestors. Between 12:30 pm to 2:30 pm, shall conduct a Seminar on "Suffering, Identity, Culture, Buddhism and Rights of Khmer Krom People".

EVENING

- 6:00PM = Arrival of members and distinguished guests at the **Dutch Canadian Center, 13312 142 Street, Edmonton AB T5L 4T3**
- Delegates of Khmer Kampuchea Krom Federation deliver a speech about the activities of World Khmer Kampuchea Krom Federation

Follow by **Khmer Band Entertainment with Free Entrance (Accept Donation)**

More information, please contact:

Pheng Tang: 403-343-9114, Lam Lui: 780-672-4466, Dao Rith 403-649-3873
Triev Chephong 780-672-5310, Lee Son: 403-689-0699
Dao Houn: 403-669-2119, Pheak H. Son: 403-969-9842 info@kampucheakrom.ca